**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មាន

# សេចក្តីជូនព័ត៌មាន

តបតាមការអញ្ជើញរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម ថងលូន ស៊ីសូលីត នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឯកឧត្តម រ៉ូឌ្រីហ្គោ រ៉ូ ឌុយតឺតេ ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន ឯកឧត្តម ង្វៀន សួនហ៊្វុក នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម តំណាងប្រមុខរដ្ឋ/រដ្ឋាភិបាល និងរដ្ឋមន្ត្រីជាច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នឹងអញ្ជើញមកចូលរួម «វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន» ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០ ដល់ ១២ ខែឧសភា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា។

វេទិកាដែលនឹងរៀបចំឡើងដោយព្រះរាជាណាចក្រកម្ពុជា ក្រោមមូលបទ «យុវជន បច្ចេកវិទ្យា និងកំណើន៖ ការធានាពីគុណប្រយោជន៍ផ្នែកប្រជាសាស្ត្រ និងឌីជីថលរបស់អាស៊ាន» នឹងមានការអញ្ជើញចូលរួមផងដែរពីអ្នកធ្វើការសម្រេចថ្នាក់ខ្ពស់ពីផ្នែកឧស្សាហកម្ម ហើយនិងឥស្សរជនសំខាន់ៗលើវិស័យធុរកិច្ច ផ្នែកស្រាវជ្រាវ និងសង្គមស៊ីវិល។

វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានឆ្នាំ២០១៧ នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការរួមចំណែកពីកំលាំងការងារវ័យក្មេង និងប្រកបដោយថាមពល ដែលកំពុងកើនឡើងនៅក្នុងតំបន់ ក្នុងការស្ថាបនាអនាគតដ៏ត្រចះត្រចង់របស់តំបន់។ វេទិកានេះក៏នឹងផ្តល់កាលានុវត្តភាពសំរាប់ការលើកស្ទួយកិត្តិនាមអន្តរជាតិ និងមោទនភាពជាតិរបស់កម្ពុជា។ លើសពីនេះទៅទៀត វេទិកានេះនឹងរួមចំណែកដល់ការលើកតំកើងកាលានុវត្តវិស័យវិនិយោគ និងទេសចរណ៍របស់កម្ពុជា ដែលភាគច្រើននៃសក្តានុពលដ៏ធំនេះមិនទាន់ត្រូវបានយកមកប្រើប្រាស់នៅឡើយ។

វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានឆ្នាំ២០១៧ ត្រូវបានរំពឹងទុកថា នឹងផ្តល់លទ្ធផលប្រកបដោយផ្លែផ្កា ដើម្បីលើកកំពស់ថែមទៀតដល់ការអភិវឌ្ឍប្រកបដោយចីរភាព សន្តិភាព ស្ថិរភាព និងវិបុលភាព ដែលរួមចំណែកដល់ការកសាងសហគមន៍អាស៊ានដ៏រឹងមាំមួយ។

ភ្នំពេញ, ថ្ងៃទី៥ ខែ ឧសភា ឆ្នាំ ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh

Scanned by CamScanner